# ការសម្ភាសន៍របស់បងប្រុស ពក ប៉េង

ក៖ អ្នកសម្ភាសន៍ឈ្មោះ ម៉េត អេងសួរ ខ៖ អ្នកត្រូវបានសម្ភាសន៍ឈ្មោះ ពក ប៉េង

## <u>សង្ខេបរបស់បងប្រុស ពក ប៉េង</u>

បងប្រុស ពក ប៉េង មានអាយុ ៤៨ មានស្រុកកំណើតនៅភូមិ ឈើទាលស្រុតលើ ឃុំរំចេក ស្រុកកំពុងសៀម ខេត្តកំពុងចាម ។ បងប្រុសមានប្រពន្ធឈ្មោះ ស៊ិប ស្រី នឹងកូនប្រុស ២នាក់ឈ្មោះ ប៉េង សុខពេជ្រ នឹង ប៉េង ៧ ។ បងប្រុសមានឪពុកឈ្មោះ ពក នឹងអ្នកម្ដាយឈ្មោះ អ៊ាង ដែលបងប្រុសមានបងប្អូនបង្កើត ២នាក់ដែលប្អូនរបស់គាត់ឈ្មោះ ពក សុខផេង ។

ក៖ អ៊ំរ ... ជាដំបូងញ៉ុមសុំថ្លែងអំណរគុណដល់បងញ៉ុមហៅបងហីណាបង ?

ខ៖ បាទ!

ក៖ ហ្នឹងហី! អ៊ំរ ... ដែលអោយញ៉ុមសម្ភាសន៍នៅថ្ងៃហ្នឹង ហើយការសម្ភាសន៍នេះគឺធ្វើឡើងដោយសកលវិទ្យាល័យមួយនៅ សហរដ្ឋអាមេរិច ដែលមានឈ្មោះថា BYU ដែលសកលវិទ្យាល័យមានគោលបំណងចង់ចងក្រងអ៊ំរ ... ប្រវត្តិរបស់ប្រជាជនខ្មែរទាំងអស់ដាក់ចូលក្នុងវេបសាយមួយដែលមានឈ្មោះថាអ៊ំរ ... WWW.cambodianoralhistories.byu.edu អញ្ចឹងអ៊ំរ ... ញ៉ុមចង់សុំអនុញ្ញាតិបងតើញ៉ុមអាចយកការសម្ភាសន៍របស់បងហីហ្នឹងញ៉ុម ថ្ងៃនេះដាក់ចូលក្នុងវេបសាយរបស់សាលាបានអត់ ?

ខ៖ បាន!

ក៖ ហ្នឹងហី! អញ្ចឹងអគុណច្រើនបង ។ ហីចំពោះការសម្ភាសន៍របស់យើងថ្ងៃនេះគឺធ្វើឡើងនៅ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៨ ។ នៅភូមិ ឈើទាលស្រុតលើ ឃុំរំចេក ស្រុកកំពុងសៀម ខេត្តកំពុងចាម ។ អញ្ចឹងសំនួរជាដំបូងដែលញ៉ុមចង់សួរទៅបង តើអ៊ំរ .... បងមានឈ្មោះអីដែល ?

ខ៖ ឈ្មោះ ប៉េង ។

ក៖ អ៊ំរ ... ឈ្មោះពេញឈ្មោះអីដែលបង ?

ខ៖ ត្រកូល! នាមត្រកូលម៉ងហំ ?

កៈ ចាស!

ខៈ ពក ប៉េង ។

កៈ ពក ប៉េង! ចុះបងមានឈ្មោះហៅក្រៅអីអត់ ?

ខៈ អត់មានទេ! អត់មានទេ!

កៈ អត់មានទេណ៎ ? អ័រ .... ចុះក្នុងឆ្នាំហ្នឹងបងមានអាយុមាណហឺ ?

ខៈ ៥៨!

កៈ ៥៨! តើបងបងកើតឆ្នាំអីដែលបើជាឆ្នាំខ្មែរ ?

ខៈ ឆ្នាំ! ឆ្នាំ ច ។

កៈ ឆ្នាំ ច ណ៎ ? អ័រ .... បងអាចរៀបរាប់ ថ្ងៃ ខែ ឆ្នាំ កំណើតរបស់បងបានអត់ ?

ខៈ អត់ចាំដែល! ទាល់នៅក្នុងនេះហ៎ ....

កៈ នៅក្នុង ....

ខៈ ចេះដាក់ព្រាវៗដែលមើលទៅក្នុងណុង ។

កៈ ក្នុងអត្តសញ្ញាណប័ណ្ណ ?

ខៈ ហ្នឹងហ៊ី!

កៈ ចុះបងមានអត្តសញ្ញាណប័ណ្ណអត់ ?

ខៈ មានតា!

កៈ ហ្នឹងហ៊ី! Ok ចុះអ័រ .... ចំពោះកន្លែងកំណើតរបស់បងវិញ តើបងកើតនៅកន្លែងណា ?

ខៈ កើតនៅភូមិហ្នឹងម៉ង! ឈើទាលស្រុតលើ ហ្នឹងម៉ង ។

កៈ អាចរៀបរាប់ទាំង ភូមិ ទាំងឃុំ ....

ខៈ ឈើទាលស្រុតលើ ឃុំរំចេក ស្រុកកំពុងសៀម ខេត្តកំពុងចាម យើងហ្នឹងហា ។

កៈ ចាស!

ខ៖ អើ!

ក៖ ចុះបងមានបងប្អូនចំនួនមាណនាក់ដែលនៅក្នុងគ្រួសារ ?

ខ៖ ២នាក់!

ក៖ អាចរៀបរាប់ឈ្មោះគាត់បានអត់ ?

ខ៖ ឈ្មោះអាលែង .... វាដាក់ឈ្មោះ ពក សុខផេង ញ៉ុម ពក ប៉េង ប្អូនញ៉ុម ពក សុខផេង ២នាក់ហ្នឹង ។

ក៖ អ័រ .... ស្រីទាំង២ ឬក៏ប្រុសទាំង២ ?

ខ៖ ប្រុស១ ស្រី១ ។

ក៖ ចុះបងជាកូនទីមាណដែល ?

ខ៖ កូនទី១ ។

ក៖ កូនទី១ណ៎ ?

ខ៖ បាទ!

ក៖ ចុះកាលនៅពីតូចបងមានចងចាំសាច់រឿងអីជាមួយគាត់អីអត់ ?
អនុស្សាវរីយ៍អីជាមួយគាត់អញ្ចឹងហាណា ?

ខ៖ ប្អូនហ៎ ?

ក៖ ចាស!

ខ៖ ហ៊ឹម! ជំនាន់ណុងវានៅតូចតែជំនាន់អាលែងយើង .... អាលែង ប៉ុល ពត យើងហ្នឹងណុង ខ្មែរក្រហម ហ្នឹងវាខ្វិនមីប្អូនណុងហ៎ ។

ក៖ ចាស!

ខ៖ ខ្វិនដើរមានរួចណា យើងតាថៃ .... បងគេទៅដើរយកបបរអោយវាហ្នឹងហា!
កាលណុងខ្វិនដើរអត់រួចទេទាល់តែដាច់ទៅហ្នឹងបានដើររួចហ៎ ។

កៈ អ! កាលជំនាន់ ប៉ុល ពត ហេ ? ប៉ុន្តែអ័រ .... ដល់ពេលយើងខ្ញុំនអញ្ចឹង ប៉ុល ពត ហ្នឹងមានធ្វើអីយើងអត់ ?

ខៈ គ្មានទេ! វាដេកនៅនឹងកន្ទេលយើងយកតែបបរមកអោយវាស៊ី រហូតទាល់តែដាច់បានវាដើរព្រើកៗ ។

កៈ អ! អញ្ចឹងគេអត់មានធ្វើបាបអីយើងទេណ៎ ?

ខៈ បា!

កៈ ចុះនៅពេលដែលបងនៅក្មេង បងចូលចិត្តធ្វើអីគេជាមួយពួកគាត់ ?

ខៈ មានធ្វើអីទេ ដើរតែលេងនៅពីក្មេង (សើច) មិនដឹងធ្វើអីហ៎ ។

កៈ ចុះឥឡូវបងស្រីគាត់ .... គាត់អ័រ ... ជាពីពិការវិញនៅ ?

ខៈ ជាហើយ! មានប្ដីមានកូនអស់ហើយ ។

កៈ អញ្ចឹង! ចុះឥឡូវគាត់រស់នៅឯណា ?

ខៈ នៅហ្នឹងដែលតា! ឈើទាលស្រុតលើ ដែលហ្នឹង ។

កៈ គាត់ធ្វើការអីគេទៅ ?

ខៈ ហ៊ឹម! របរកសិក ធ្វើស្រែចំការហ្នឹង ។

កៈ ហ្នឹងហើ! មិញហ្នឹងរៀបរាប់អំពីឪពុក .... អំពីបងប្អូនរបស់បងអញ្ចឹងចង់ដឹងអំពីឪពុកម្ដាយរបស់បងវិញ តើពួកគាត់មានឈ្មោះអីខ្លះទៅ ?

ខៈ គាត់ ប៉ាញ៉ុមឈ្មោះ ពក ម៉ែឈ្មោះ អ៊ាន ។

កៈ អាចរៀបរាប់ពីត្រកូលរបស់គាត់បានអត់ ?

ខៈ គាត់មិនដឹងគាត់ដាក់ត្រកូលអីផងកាលណុង បើគាត់ស្លាប់តាំងពីញ៉ុមនៅតូចដែល ។

កៈ អ!

ខៈ ប៉ុល ពត ចាប់យកទៅហ៎សំលាប់ហ៎! ប៉ាញ៉ុមនៅតែម្ដាយហ្នឹង! ដឹងគាត់ឈ្មោះអីដាក់ត្រកូលអីគាត់ ។

កះ ចុះថីបានគេចាប់គាត់យកទៅអញ្ចឹង ?

ខះ គាត់កាលណុងគាត់ធ្វើការជំនាន់ ប៉ុល ពត ហ្នឹងហា ។

កះ ចាស!

ខះ រួចដល់ពេលនេះគេចាប់ទៅ ... សំលាប់ ។

កះ អ! ជំនាន់ណុងអោយតែអ្នកធ្វើការអ្នក ចេះដឹងគេយកទៅ ?

ខះ បា! គេចាប់ហើយកទៅបាត់ទល់ឥឡូវហ្នឹងទៅណា ។

កះ ចាស!

ខះ ងាប់បាត់ទៅ ។

កះ ចុះអ័រ ... ម្តាយរបស់បងអត់ទាន់ ... គាត់នៅតាហឺបង ?

ខះ នៅ! នៅ! រាល់ថ្ងៃគាត់នៅជាមួយប្អូនណុងណា ។

កះ ចាស! ចុះអ័រ .... បើសិនជាបងស្មានហាអាយុរបស់ឪពុកបងហាអាយុមាណហឺ ?

ខះ អាយុគាត់ .... មើល! គាត់ ៦០ហឺ ៦០ .... ញ៉ុម ៥០ជាងហឺគាត់ ៦០ជាងហឺ ។

កះ ចាស!

ខះ បា!

កះ ចុះម្តាយរបស់បងវិញ ?

ខះ ណុងហឺគាត់អាយុស្មើរគ្នាតាស! ស្រករគ្នា ៦០ជាងដូចគ្នា ។

កះ ចុះបងមានអ័រ ..... ចងចាំ ថ្ងៃ ខែ ឆ្នាំ របស់គាត់អីអត់ ?

ខះ អត់! អត់ដឹង!

កះ អ័រ ... Ok អញ្ចឹងម្តាយរបស់បងឥឡូវរស់នៅជាមួយប្អូនស្រីរបស់បងនៅក្នុងអ័រ ... ភូមិឈើទាលស្រុតលើ ហ្នឹងដែលណំ ? ហ្នឹងហឺ! ចុះអ័រ ... កាលពីមុនហ្នឹងឪពុករបស់បងគាត់ប្រកបមុខរបរអីគេចិញ្ចឹមជីវិត ?

ខ៖ គាត់អ្នកស្រែ ចំការដូចតែយើងដែលហ្នឹង ប៉ុនដល់ពេលជំនាន់នេះហ្នឹងទៅគេ ដូចថាគេរកអ្នកចេះដឹងហា!
ធ្វើស្មៀនហ្នឹងគេអញ្ចឹងទៅដល់ពេលគាត់ធ្វើអញ្ចឹងទៅគេអោយឡើងអញ្ចឹងហា ។
ធ្វើមេគេអញ្ចឹងទៅ ដល់ពេលនេះទៅគេចាប់យកទៅបាត់ទៅ ... នៅតូចដែល ។

ក៖ ចុះគាត់ធ្វើបានច្រើនឆ្នាំអត់ស្មៀនហ្នឹង ?

ខ៖ គាត់ធ្វើបានយូឆ្នាំដែលហា ទល់តែពេលអាលែងនេះគេ ....
គេអាលែងនេះពួកអាលែងនេះចូលមកគេចាប់គាត់ទៅណុងហា ។ គាត់ក្តាប់នៅខាង កៀន ជ្រៃ ខាងអីណុងហាប៉ុន្មានឃុំ ។

ក៖ ចុះអ័រ ... ចំពោះអត្តចរិករបស់គាត់បងអាចនៅចងចាំអត់ តើគាត់មាន ... ជាមនុស្សបែបណាទៅ ?

ខ៖ មនុស្សគាត់ស្លូតបូតហ្នឹងណាបានគេចូលចិត្តគាត់ហ្នឹង ។

ក៖ អ!

ខ៖ គាត់អ្នកធម៌ដែលណុង គាត់បានបួសបានរៀនដែរ ។

ក៖ ចាស!

ខ៖ អើ!

ក៖ ចុះសំរាប់ម្តាយរបស់បងវិញ តើគាត់ចិញ្ចឹមអ័រ .... គាត់ប្រកបមុខរបរអីគេសំរាប់ចិញ្ចឹមជីវិត ?

ខ៖ គាត់មុខរបរគាត់ស្រែ ចំការ ហ្នឹងលក់ដូរតិចតួចគ្រាន់ចិញ្ចឹមកូនហ្នឹងហា ។

ក៖ ចុះចំពោះអត្តចរិករបស់គាត់វិញ ?

ខ៖ អើ! គាត់មានអីស្លូតបូតតើ ។

ក៖ អញ្ចឹងឪពុកម្តាយរបស់បងស្លូតបូតទាំង ២នាក់ណេ៎ ?

ខ៖ បា! បា!

ក៖ អត់មាននរណាគេកាចអីមួយទេណេ៎ ?

ខ៖ អត់ទេ! កាចយើងមួយមិចបើកាច ។

ក៖ ក្រែងលោគាត់ពូកែរអ៊ូអីអញ្ចឹងហាណា ។

ខ៖ អត់ទេ! មិនដែលរអ៊ូទេ ។

ក៖ អញ្ចឹងបងមានចងចាំសាច់រឿង ឬក៏អនុស្សាវរីយ៍អីជាមួយពួកគាត់ហេ ទាំងម្ដាយទាំងឪពុកហា ?

ខ៖ ចងចាំដែល គាត់អ្នកមានគុណចិញ្ចឹងយើងតាំងពីតូចមកយើងអត់មានឪណា!

ក៖ ចាស!

ខ៖ រួចអាលែងគាត់ប្រឹងរកស៊ីចិញ្ចឹងយើងហ្នឹងហា គាត់ឈឺផងអីផងកាលណុងហាំ
ដើរទូលអត់កង់អីជិះទេទៅលក់ដូរណា ។

ក៖ ចាស!

ខ៖ យកមកចិញ្ចឹមកូន ២នាក់ហ្នឹងល្មមបានធំធាត់ បានរៀនបានសូត្រហ្នឹងហា!
បានប្ដីបានប្រពន្ធអស់ទៅហ្នឹងបានគាត់ទៅនៅជាមួយប្អូនហ្នឹងទៅទល់សព្វថ្ងៃហ្នឹង ។

ក៖ ចាស!

ខ៖ បា!

ក៖ ចុះមានអីទៀតហេបងដែលបងចងចាំបំផុតជាមួយគាត់
អនុស្សាវរីយ៍ដែលចងចាំខ្លាំងបំផុតជាមួយគាត់អញ្ចឹងហា ?
ដែលបងថាដក់ជាប់ក្នុងអារម្មណ៍ម៉ងហា ?

ខ៖ ចងចាំគ្មានអីទេ មានតែអាលែង .... អាណិតគាត់អញ្ចឹងហា!

ក៖ ចាស!

ខ៖ គាត់ខំប្រឹងថៃយើងពីតូចមក
មិនទាន់បានអីសងគុណគាត់ទេឥឡូវនេះបើយើងអាតតែចិញ្ចឹមកូនដែរនៀក!
មិនទាន់បានរកអីបានមានបានជួយគាត់វិញណា ។

ខ្មែរយើងតែប៉ុនហ្នឹងអោយតែបាននេះហ្នឹងអាលែងសងគុណគាត់ណុង តែមិនដឹងបានអីសង ? បើមិនទាន់រកបាននៅក្រដែល ។

កៈ ចាស! ចុះអ័រ .... គាត់មានធ្លាប់អ័រ ... ប្រាប់ពីរឿងរាវរបស់គាត់កាលនៅពីតូចៗ ឬក៏ប្រវត្តិជូចត់របស់គាត់ដល់បងអត់ ?

ខៈ គាត់មិនដែលប្រាប់យើងទេ បើគាត់អត់មាន ... យើងអត់មានធ្វើអីអោយគាត់អាលែងពិបាកផង ។

កៈ អ័រ ... ចង់និយាយថាប្រវត្តិជូចត់របស់គាត់ហា ឧទាហរណ៍ថាគាត់ធ្លាប់ជួបនឹងរឿងពិបាកអីគេដែលពិបាកខ្លាំងបំផុតក្នុងជីវិតរបស់គាត់ ហីគាត់យកមកប្រាប់អ័រ ... បងអីអញ្ចឹងហាណា ។

ខៈ គាត់មានប្រាប់តែរឿង គាត់ដើររកហ្នឹងហា! យកមកអោយយើងហ្នឹងហាលក់ដូរទៅស្រែទៅអីហ្នឹង ។

កៈ ចាស!

ខៈ ទូលទាំងក្បាលដើរទៅ ទៅលក់ទៅដូរហ្នឹងលួមបានយកមកអោយយើង ... ចិញ្ចឹមកូនទាំង២ហ្នឹងបានធំធាត់ទល់ឥឡូវហ្នឹងទៅ គាត់ប្រឹងហាណាពេលគាត់ទៅលក់ដូរហ្នឹងហ៎ ។

កៈ ចាស! ចុះមកទល់ឥឡូវគាត់នៅរកស៊ី ឬក៏គាត់អ័រ ... ឈប់សំរាកហី ?

ខៈ គាត់នៅរកតិចតួចជាមួយកូនណុង បើកូនធ្វើចំការអីទៅជួយអញ្ចឹងទៅណា មើលចៅមើលអីទៅ ។

កៈ អូ! គាត់ចាស់ហីនៅតែរកទៀត ?

ខៈ បា! បើមិនរកបានអី ? បើក្រ ។

កៈ ក្រែងលោកូនចិញ្ចឹមហា ។

ខៈ អឺ! កូនវេទនាដែលហ្នឹងហាគ្នា! គាត់ទៅហើយចំការរាល់ថ្ងៃហ្នឹងទៅធ្វើហ្នឹងជាមួយនឹងកូនហ្នឹង ។

កៈ ចុះគាត់ធ្វើចំការនៅណាវិញ ?

ខៈ ចំការក្រោយ! ខាងលិចណុងហ៎! ទុងកោះ ណុង ។

កៈ ចាស! ដើរទៅ ?

ខៈ ដើរទៅ ទូកទៅ ជិះទៅ មានទូកជិះទូកទៅគ្មានទូកដើរទៅវាងតាមក្រោយវត្តហ៎ ។

កៈ ចុះបងមានចងចាំអំពីជីដូនជីតារបស់បងអត់ ? អ័រ .... ចងចាំថាគាត់ឈ្មោះអីខ្លះអីអញ្ចឹងហា ?

ខៈ ជីដូនជីតាមិនដឹងឈ្មោះអីៗទេបើច្រើនម៉េស ?

កៈ អ័រ .... លើកតែខាងម្ដាយហើយនឹងខាងឪពុកមកបានហើបង ។

ខៈ ជីដូនជីតាមានខាងប៉ាញ៉ុមឈ្មោះកុង ញឹង បើខាងម៉ែញ៉ុមនោះឈ្មោះកុង អ៊ឹម ។

កៈ ចុះ! ចុះយាយ ?

ខៈ យាយ! យាយ ម៉ៅ ខាងកុង អ៊ឹម ដូចម៉ា លីម តាប៉ុនណឹង ។

កៈ ចាស! អ័រ ... ចុះដឹងពីថ្ងៃ ខែ ឆ្នាំ កំណើតរបស់គាត់អត់ ?

ខៈ អត់ដឹង! ខ្លួនឯងចង់យ៉ាប់ផងទៅដឹងអីណា! (សើច)

កៈ ហ្នឹងហី! ចុះទីកន្លែងកំណើតរបស់គាត់អាចចាំអត់ ?

ខៈ ទីកំណើតគាត់ខាងឪពុកនៅខាង ឈើទាលស្រុតលើ យើងហ្នឹងដែរ ។
បើខាងម្ដាយគាត់នៅខាង ភូមិថ្មី ។

កៈ ភូមិ ថ្មី ?

ខៈ បា! ខាង រំលិច ហ៎ ។

កៈ អ័រ ... អាច! អាច! អាចនិយាយពីភូមិ ឃុំ ស្រុក របស់គាត់បានអត់ ?

ខៈ ឃុំភូមិ ថ្មី ហ្នឹង ឃុំ រំចេក ដែលតាស! នៅ រំលិច យើងហ្នឹង! ឃុំរំចេក ស្រុកកំពុងសៀម
ខេត្តកំពុងចាម ដូចគ្នាតាស ។

កៈ អ! ចាស!

ខៈ បា!

កៈ ចុះអ័រ .... អ័រ ... ម្ដាយឪពុករបស់បងធ្លាប់និយាយពីប្រវត្តិរបស់ជីដូនជីតារបស់បងប្រាប់ ... ប្រាប់បងអត់ ?

ខៈ អត់ដែលទេ ។

កៈ ចុះចំពោះក្រុមគ្រួសាររបស់បងរស់នៅក្នុងខេត្ត កំពុងចាម ហ្នឹងយូហើយនៅបង ?

ខៈ តាំងពីតូចមកម្ល៉េះ ។

កៈ តាំងពីតូចមកម៉ងណំ ?

ខៈ បាទ! កំណើតកើតជានៅហ្នឹងទាំងអស់ម៉ង ។

កៈ អ័រ ... មិញបងថាបងអាយុមាណឆ្នាំហី ?

ខៈ ៤៨!

កៈ អ! អញ្ចឹង ៤៨ឆ្នាំហើយណំ ?

ខៈ បាទ!

កៈ ចុះបងមានសាច់ញាតិរស់នៅក្រៅប្រទេស ក្រៅពីប្រទេសខ្មែរអត់ ?

ខៈ អត់មានផង ។

កៈ អត់មានពីណាគេទៅ កូរ៉េ ទៅអីហេណំ ?

ខៈ ហ្នឹងហី! អត់មានទៅហេ នៅតែធ្វើចំការទាំងអស់ ។

កៈ ហ្នឹងហី! ចុះចំពោះឥឡូវហ្នឹងបងអ័រ ... មានគ្រួសារនៅបង ?

ខៈ ញ៉ុមហ៎ ?

កៈ ចាស!

ខៈ មានហើយ ។

កៈ គ្រួសារបងឈ្មោះអីគេបង ?

ខៈ ឈ្មោះ ស៊ិប ស្រី ។

កៈ សិុប ស្រី ?

ខៈ បាទ!

កៈ ចុះបងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែលបង ?

ខៈ ញុំមរៀបតាំងពី .... ៨៩ ម្ល៉េះ ។

កៈ ៨៩ ?

ខៈ បា! មកទល់ឥឡូវប៉ុន្មានឆ្នាំហើយគិចមើល ?

កៈ ៨៩ ?

ខៈ អើ!

កៈ ៨៩ ? ប្រហែលចង់ ១០ ...

ខៈ ៣០!

កៈ អត់ដល់ ៣០ ទេ ... ២៩! ២៩ ។

ខៈ ៨៩! តាំងពី ១៩៨៩ ម្ល៉េះ ។

កៈ ថា ២៩ឆ្នាំ ចុះ ។

ខៈ បា!

កៈ ហ្នឹងហី! អ័រ ... ចុះបងចាំថ្ងៃ ខែ ដែលបងរៀបការអត់ ?

ខៈ អត់! អត់ចាំផង!

កៈ ដឹងតែឆ្នាំទេណ៎ ?

ខៈ បា! ដឹងតែឆ្នាំ ។

កៈ ចុះអ័រ ... ចំពោះអាពាហ៍ពិពាហ៍របស់បងហ្នឹងបងរៀបចំឡើងដោយខ្លួនឯង ឬក៏ម្ដាយឪពុកអ្នករៀបចំ ?

ខៈ ម្ដាយឪពុកអ្នករៀបចំ ។

កៈ ចាស!

ខៈ បា!

កៈ ចុះបងជូនជំនួនទៅបងស្រីប៉ុន្មានដែល ?

ខៈ កាលណុងស៊ីស្មើរគ្នា (សើច) ស៊ីស្មើរគ្នា ។

កៈ ស្មើរគ្នាមិចទៅ ?

ខៈ ស៊ីស្មើរគ្នា ដូចថាយើងប្រាប់ ១០ទៅគាត់ខាងស្រី ១០ទៅណា ។

កៈ អញ្ចឹងអត់មានជំនួនទេហ៎ ?

ខៈ អត់! វាស្រួលដែល ។ (សើច)

កៈ ចុះ ....

ខៈ គ្មានក្លូចដៃក្លូចជើងអីទេ ។

កៈ អត់មានគេហៅអីគេ ? បណ្ណាការហី ?

ខៈ អត់មានទេ!

កៈ ចុះអ័រ .... បងជួបគ្នានៅពេលណាទៅបានបងសំរាចចិត្តរៀបការជាមួយគ្នា ?

ខៈ នៅផ្ទះជិតគ្នាដែលដល់ពេល អាលែងម៉ែឪត្រូវចិត្តទៅ ក៏ចូលដណ្តឹងអីទៅណា! កាលណុងហា! រួចទៅបានរៀបការទៅ ។

កៈ អត់ពេញចិត្តខ្លួនឯងហេ ?  គ្រាន់តែម៉ាក់ប៉ាអ្នក ... អ្នកឃើញខ្លួនឯងមែន ?

ខៈ ទេ! តាស្រាច់តែសំរាចលើគាត់កាលហ្នឹង! គ្មានទៅពេញចិត្តពេញថ្លើមអីខ្លួនឯងដើររើសទេ គាត់ថាណាណុងទៅណា ។

កៈ ចាស!

ខៈ តាមគាត់ ។

កៈ ចុះបើកូនក្រមុំគាត់ដណ្តឹងអោយអត់ស្អាតយកអត់អញ្ចឹង ?

ខ៖ អត់ស្អាតអត់យកដែរណុងហា ។

ក៖ អញ្ចឹងមានន័យថាបងស្រីស្អាតហី បានយកមែនអត់ ?

ខ៖ មានអី ។

ក៖ ត្រូវចិត្តហីហ្នឹងហ៎ ?

ខ៖ ហ្នឹងហី! ត្រូវចិត្តហីបានទល់តែសព្វថ្ងៃហ្នឹង ។

ក៖ ចុះអ័រ ... បងអាចនិយាយភាសាខ្មែរទាំងអានទាំងសសេរបានល្អអត់ ?

ខ៖ បា! ញ៉ុមមិនសូវបានមាណដែលទេ ។

ក៖ មិនសូវបានមាណទេណ៎ ? ចុះភាសាបរទេសវិញ
តើមានភាសាណាដែលបងចេះក្រៅពីភាសាខ្មែរអត់ ?

ខ៖ អត់ចេះសោះ! (សើច) ដូចថាម៉ែឪក្រមានបានរៀនឯណា ?

ក៖ អ!

ខ៖ គ្មានទេ!

ក៖ ចុះកាលជំនាន់ណុងបងរៀនបានថ្នាក់ទីប៉ុន្មានដែរ ?

ខ៖ ថ្នាក់ទី ៥ ។

ក៖ ថ្នាក់ទី ៥ ?

ខ៖ បា!

ក៖ ចុះបងរៀននៅអ័រ ... បឋមសិក្សាណាគេ ?

ខ៖ មាន់ហើរ យើងហ្នឹង ។

ក៖ បឋមសិក្សាឈ្មោះអីគេ ?

ខ៖ ដាក់អ័រ ... កាលណុងបឋមអ័រ ... អ័រ ... ហាន់ជ័យ! ហាន់ជ័យ ។

ក៖ បឋមសិក្សា ហាន់ជ័យ ?

ខ៖ បា!

ក៖ ចុះកាលជំនាន់បងរៀនហ្នឹង បងមានមិត្តភ័ក្តស្និទ្ធស្នាលបំផុតអីអត់ ?

ខ៖ គ្មានទេ! គ្មានមិត្តភ័ក្តទេរៀនហា ... មិត្តភ័ក្តទាល់តែយើងមានលុយដើរណា ។

ក៖ ចាស!

ខ៖ ទៅស៊ី ចាយហ្នឹងគេយើងអត់មាន! ចេញលេងមិនទាំងហានចេញផងនៅតែក្នុងថ្នាក់ហ្នឹងទៅ ។ ម៉ែឪក្រធ្វើមិចហ៎ ? បានតែ ៥កាក់ទៅហ្នឹងអគុណហា!

ក៖ តែមិត្តភ័ក្តមានទាក់ទងនឹងលុយណាបង ឧទាហរណ៍ថាអ្នកដែលអង្គុយជិតយើងអីអញ្ចឹង ។

ខ៖ មិត្តភ័ក្តហ្នឹង យើងដើរលេងយប់ព្រលប់អីហ្នឹងជំនាន់ណុង ។

ក៖ ហ្នឹងហើ!

ខ៖ គ្នាឯងជិតៗខាងហ្នឹងហា!

ក៖ អញ្ចឹង ...

ខ៖ បើថាអោយអ្នក ... មិត្តភ័ក្តទៅឆ្ងាយៗគ្មានទេ ។

ក៖ ចាស!

ខ៖ មានតែជិតខាងជាប់ផ្ទះគ្នាហ្នឹង ។

ក៖ អាចលើកឈ្មោះគាត់ម្នាក់បានអត់បង ?

ខ៖ មិត្តភ័ក្តហ៎ ?

ក៖ ចាស!

ខ៖ មិត្តភ័ក្តមានដូចជាអា ... អាធឿន អីហ្នឹងនៅជាប់ផ្ទះគ្នាហ្នឹងហា ។

ក៖ ចាស!

ខ៖ បា!

កៈ ចុះកាលជំនាន់ណុងបងមានចងចាំសាច់រឿងអីជាមួយបង ធឿន ហ្នឹងអត់ ? ធ្លាប់ទៅលេងអីណា? ទៅស្រែ ...

ខៈ ធ្លាប់ទៅលេង ធ្លាប់ដើរលេងអីអញ្ចឹងដែលខែចូលឆ្នាំ ... មានតែអញ្ចឹង ។

កៈ អត់មានធ្លាប់លេងបាញ់ឃ្លីលេងអីជាមួយគ្នាទេណ៎ ?

ខៈ ធ្លាប់រឿងបាញ់ឃ្លី បាញ់យុយហ៎កាលជំនាន់ណុងហ៎ ។

កៈ ចុះឥឡូវគាត់នៅណាវិញ ?

ខៈ ឥឡូវគេទៅនៅ រតនៈគិរី ។

កៈ អ!

ខៈ ឆ្ងាយ!

កៈ ចុះបងដែលទាក់ទងជាមួយគាត់អត់ ?

ខៈ អត់!

កៈ អត់ទេណ៎ ?

ខៈ ហ្នឹងហើ!

កៈ ចុះអ័រ ... បងធ្លាប់ធ្វើការនៅវាលស្រែអត់បង ?

ខៈ វាលស្រែ ?

កៈ ចាស! ធ្វើស្រែចំការយើងហ៎!

ខៈ អ! ស្រែចំការរាល់ឆ្នាំ ។

កៈ ចំជំនាញប៉ាដោយ ។

ខៈ ចំជំនាញម៉ងហា! អោយតែទឹកសំរកហ្នឹងដឹងតាចូលហា ។

កៈ ចុះចំពោះអាជីវកម្មរបស់បងវិញក្រៅពីការធ្វើស្រែ ចំការ បងមានធ្វើអីផ្សេងអត់ ?

ខៈ គ្មានទេ! ចំការ ... ចប់ពីធ្វើចំការមកចុះបឹងដកក្រអៅវឈ្យូកក្រអៅវអីហ្នឹងរហូតទៅអញ្ចឹង ។

កៈ ហ្នឹងហី!

ខៈ មុខរបរយើងហើយហ្នឹងហ៎ ។

កៈ ចាស!

ខៈ មួយឆ្នាំទល់មួយឆ្នាំទល់តែទឹកចូលមកវិញ លិចអស់បានលែងបានម៉ងអាណុង! លែងរកហី ។

កៈ ចុះមានអីផ្សេងទៀតអត់ ?

ខៈ បា! អត់មានទេ! ដល់ ... ដល់ពេលទឹកលិចទឹកសំរកទៅធ្វើការទៀតហា ប្រាំងទៀតហាអញ្ជឹង ។

កៈ ចុះម៉ាឆ្នាំសំរាកបានមាណខែចឹង ?

ខៈ ដូចគ្មានបានសំរាកផងហ្នឹង ។

កៈ ធ្វើរហូតអញ្ជឹងហីបាន បានលុយច្រើន ។

ខៈ ហ្នឹងហី! ធ្វើរហូតតែជញ្ជាំងនៅតែដែកដដែលហ្នឹង ។

កៈ ចុះបើទុកទិញឡាន ទិញអី ។

ខៈ គ្មានទេ! រកណាបានទិញ ទិញ ។

កៈ អ័រ ... ចំពោះការ .... ការស្មានរបស់បងហាណាបងគិតថាតាំងពីជីវិតរបស់បង តាំងពីតូចរហូតមកដល់ពេលនេះមានអ្វីផ្លាស់ប្តូរអត់ ? បងគិតប្រមាលមើលអញ្ជឹងហា ?

ខៈ គ្មានទេ! គ្មានអីផ្លាស់ប្តូរទេ នៅតែប៉ុនហ្នឹងមើលទៅស្រែចំការរហូតហ្នឹង ។ ព្រោះយើងអត់មានតំរិះវិជ្ជាអីហា! ដែលទៅមុខរកអីបាន មានតែស្រែចំការ ។

កៈ ផ្លាស់ប្តូរតាតាំងពីនៅកំលោះឥឡូវកូន ២ ហីមានប្រពន្ធមួយទៀត ។ ចំពោះម្ហូបអាហារវិញ តើម្ហូបអាហារមួយណាដែលបងពេញចិត្ត .... ដែលបងចូលចិត្តជាងគេ ?

ខៈ ហ៊ឹម! រាល់ថ្ងៃហ្នឹងគ្មានអីទេ ។

កៈ ចាស! ចូលចិត្តពិសារអីគេរាល់ថ្ងៃ ?

ខៈ ម្ហូបហ៎ ?

កៈ ចាស!

ខៈ មានអីមានតែ ត្រីស្មោរ ត្រីអាំងហ្នឹងទៅ ។

កៈ ហ្នឹងចូលចិត្តជាងគេហើហ្នឹងបង ?

ខៈ បា!

កៈ ហើចុះចំពោះល្បែង .... ចំពោះល្បែងប្រជាប្រិយអីវិញបងចូលចិត្តល្បែងអីគេដែលបង ?

ខៈ ហ៊ឹស! ល្បែងប្រជាប្រិយមានតារាំហ្នឹងហា! ជំនាញហើ!

កៈ អ! បងចេះរាំដែលហ៎ ?

ខៈ បា!

កៈ ចេះ! ចេះរាំចង្វាក់អីខ្លះ ?

ខៈ រាំវង់អីអញ្ចឹងទៅណាប្រពៃណីខ្មែរយើងហ្នឹងណា បើអោយកន្លាក់រាំអីមិនសូវប៉ិនទេ ។

កៈ អញ្ចឹងបងចូលចិត្តរាំ អញ្ចឹងបងចូលចិត្តច្រៀងចំរៀងអីអត់អញ្ចឹង ?

ខៈ អត់! អត់ចេះច្រៀងអត់ចេះហោ បើពូកែខាងរាំ ។

កៈ ចុះមាននរណានៅក្នុងគ្រួសាររបស់បងចេះលេងឧបករណ៍ភ្លេងអីអត់ ?

ខៈ អត់! អត់មាន ។

កៈ អត់មានទេណ៎ ?

ខៈ បា!

កៈ អ៊ែរ ... តាំងពីតូចរហូតដល់ធំផ្ទះរបស់បងមានលក្ខណះបែបណាខ្លះ ?

ខៈ តាំងពីតូចមកផ្ទះវាមាន ផ្ទះស្បូវ កាលនៅជាមួយម្ដាយហាណា ។

កៈ ចាស!

ខៈ ផ្ទះស្បូវតូចមួយ អើ! ដល់ពេលមានប្រពន្ធទៅធ្វើផ្ទះស្បូវដែល ។

កៈ ហើចុះមកដល់ឥឡូវ ?

ខ៖ មកដល់ឥឡូវបានលើកបានទ្រើសបន្តិច ២ ៣ខ្ទងហ្នឹង! បា! មិនទាន់បានជញ្ជាំង ។

ក៖ អត់ទាន់បានជញ្ជាំង ?

ខ៖ ជញ្ជាំងនៅដែករហែករហុយនៅឡើយហ្នឹងហា ។

ក៖ ចុះនេះហ៎អីគេនេះ ?

ខ៖ អាហ្នឹងទើប ... ទើបនឹងទិញមក ។

ក៖ អ! អញ្ចឹងយកមកបិទជញ្ជាំងហ្នឹងហ៎បង ?

ខ៖ អ! អត់មែនបិទទេយកមកធ្វើរនាប រនាបវាតា!

ក៖ ហាក? អ!

ខ៖ រនាប!

ក៖ អញ្ចឹងឥឡូវហ្នឹងបានផ្ទះខ្ទងហី តិចទៀតហ្នឹងបានផ្ទះវីឡាហី ដូរផ្ទះទៀត ។

ខ៖ បា! ដល់កូនរកបានហ៎! បានបានធ្វើខ្ញុំអស់ហើយណា ។

ក៖ អស់មែនទែន ?

ខ៖ ចាស់ហី! ហ្នឹងហីអស់ហើយរាល់ថ្ងៃឈឺតាមនុស្សឡើងឈាមជាង ១០ឆ្នាំហីនៀក ។

ក៖ ហ្ស!

ខ៖ ឡើងខ្លាំងមែនទែបហា ហ្ស! ក្រៅពីញ៉ុមងាប់បាត់ហីនៀក ។

ក៖ ចុះមានបានទៅពិនិត្យពេទ្យអីអត់ ?

ខ៖ ពិនិត្យតា! ពេទ្យ ... ពិនិត្យដល់ពេទ្យ បារាំង ទៀតហ៎! កប៉ាល់មកណាក!
ពិនិត្យបារាំងដល់ថ្នាក់ក្រវីក្បាលហា ។

ក៖ មិចចឹង ?

ខ៖ បើឈាមឡើងខ្លាំងហ៎! ឡើងដល់ ២២ហា ។

ក៖ អ! ខ្លាំងហី!

ខ៖ រាល់ថ្ងៃចេះតែរកទៅហ្នឹងឈើរហូតហ្នឹង ចង្អេះងើបអត់រួចឈើទាំង ២នាក់ប្រពន្ធក៏ឈឺ ។

ក៖ ចុះឥឡូវបានធូរបន្តិចនៅ ?

ខ៖ មានទេ! មានធូរទេឈើតែរហូតហ្នឹង
ចង្កេះព្រលឹមឡើងងើបមិនរួចប៉ុនចេះតែទៅរកទៅណាបានអីហ៎ ?
មានពីណាជំនួសដៃជើងកូននៅតូចៗ ប្រពន្ធក៏ឈឺវះដែលគ្នា ។

ក៖ គាត់វះអីគេបង ?

ខ៖ វះដុំពោះ ។

ក៖ អ!

ខ៖ ដុំ ... ដុំ ៤គីឡូហា! ដុំក្នុងពោះយើងហ្នឹងណា ។

ក៖ ចុះឥឡូវវះចេញនៅ ?

ខ៖ វះហើយ!

ក៖ តែអត់អីណាហី ?

ខ៖ អត់អីទេ! ៤គីឡូហាដុំណុងហាមែនតិចណា ។

ក៖ ចាស! ហ្នឹងហីជូនពរអោយបង ហើយនឹងបងស្រីឆាប់ជា ។

ខ៖ បាទ!

ក៖ ចំពោះផ្ទះដែលបងសាងសងខាងក្រោយហ្នឹង បងសាងសងដោយខ្លួនឯងណ៎បង ?

ខ៖ បា! រកលុយបានតិចតួចហ្នឹងសាងសងទៅត តទៅ ។

ក៖ បើគិតពីថវិកាវិញប្រហែលជាអស់មាណទៅបង ?

ខ៖ ក្រោយនេះហេ ?

ក៖ ចាស! ទាំងអស់ហ្នឹង ។

ខ៖ អាហ្នឹង ...

កៈ ទាំងផ្ទះទាំងអី ។

ខៈ ទាំងអស់ ... អស់ប្រហែលថាជាង ១ម៉ឺន$ហ៎ ។

កៈ ១ម៉ឺន$ណ៎ ?

ខៈ អើ!

កៈ អ! អញ្ចឹងបងពូកែបងរកលុយបានដល់ ម៉ឺន ម៉ឺនហ៎ ។

ខៈ ពូកែហើ ១ឆ្នាំបាន ១រយ ២រយចេះតែសន្សំៗទៅណា ។

កៈ ហ្នឹងហើ! អ័រ ... តើអ័រ ... គ្រួសាររបស់បងមានជំនាញអីដែលតពីកូន ...តពីឪពុកម្ដាយមកអត់បង ?

ខៈ តមកហ៎ ?

កៈ ហ្នឹងហើ!

ខៈ ហ៊ឹម! ជំនាញគ្មានអីទេ ធ្វើតែចំការដូចតែយើងដែលហ្នឹង លក់ដូរមកពីចំការអ័រ ... ធ្វើចំការចប់អញ្ចឹងទៅលក់ដូរអញ្ចឹងទៅណា ។

កៈ ចាស!

ខៈ អើ! លក់ដូររហូតអញ្ចឹងទៅទល់តែទឹកលិចទៅ ។

កៈ ចាស!

ខៈ អើ!

កៈ អ័រ ... បងអាចប្រាប់ញ៉ុមពីការលំបាកនៅក្នុងជីវិតរបស់បងបានអត់ ? ការលំបាកដែលខ្លាំងបំផុតហា ?

ខៈ លំបាកហើ ?

កៈ ចាស!

ខៈ ការលំបាកមាន ច្រើនណាស់ពីតូចមកព្រោះយើងអត់មានឪពុកប្រាប់តែខ្លួនឯង ។

កៈ ចាស!

ខ៖ នៅរៀនពេលវាកងទៅស៊ីឈ្នួលគេ ។

ក៖ ចាស!

ខ៖ យកមកចិញ្ចឹមម្ដាយណា! ទៅជំរះចំការ ជំរះអីអោយគេទៅល្មមដល់ពេលខែចូលកងវិញបាន បានមកវិញ ។

ក៖ ចាស!

ខ៖ អញ្ចឹងបានថារៀនវាមិនបានជ្រៅជ្រះ មិនបានអាលែងចេះដឹងដូចគេទេ ព្រោះយើងវាការងារវាច្រើន ។

ក៖ ចាស!

ខ៖ ស៊ីឈ្នួលគេទៅអីទៅល្មមបានបានមកលុយមក ចិញ្ចឹមជីវិតហ្នឹងតាំងពីតូចមកមានទៅបានរៀនសូត្រអីចេះដឹងដូចគេរៀន បានរៀនគួររៀនអីនឹង គេមានលុយចាយនឹងគេ ។ អញ្ចឹងបានតាថាកំសត់ពេក ។

ក៖ កំសត់ពេក!

ខ៖ ហ្នឹងហី! ប៉ុនទល់មកនេះប៉ុនចេះតែប្រឹងទៅក្រែងលោវាបាននឹង គេនឹងឯងអញ្ចឹងណា ។

ក៖ ចាស!

ខ៖ ជីវិតតស៊ូវាតាំងពីតូចមក វេទនាណាស់គ្មានឪពុកអីណាមករាប់រងទេ អញ្ចឹងបានប្រាប់កូនរាល់ថ្ងៃហ្នឹងហាថាប្រឹងទៅ ។

ក៖ ចាស!

ខ៖ ថាប្រឹងទៅវាមិនចេះអត់ទេ ។

ក៖ ចុះបងឆ្លងកាត់ការលំបាកដែលថាបងអត់មានឪពុកអញ្ចឹង តើបងឆ្លងកាត់ការលំបាកហ្នឹងយ៉ាងមិចទៅបង ?

ខ៖ ឆ្លងកាត់ហ្នឹងថាវាគ្រប់ជំពូកទៅណា! ដូចជារកស៊ីនឹងចិញ្ចឹមជីវិតហ្នឹងតាំងពីនេះមកហ្នឹងរហូត មកហ្នឹងកុំថាទៅ វាយមង វាយសន្ទូច ទៅស៊ីឈ្នួលគេហ្នឹងអោយតែបានលុយ ។

ក៖ ចាស!

ខ៖ ចេះតែដើរទៅហើរកទៅរៀន ...
ទំនេររៀនទៅជូនកាលទៅរៀនមិនទាន់ម៉ោងគ្រូស្តីអោយទៅអញ្ចឹង ដល់ ...
ដល់ពេលយើងនេះទៅយើងស្រោចទឹកក្រោកពីយប់ទៅស្រោចទឹកបន្លែអញ្ចឹង បកមកវិញរត់ ។
រួចរៀនយើងអត់កងមានអីជិះឯណាយើងក្រហ់!

ក៖ ចាស!

ខ៖ រត់ ដើរ អញ្ចឹងទៅណា! តាស្បែកជើងគ្មានពាក់ផងហ្នឹង
ខោអាវម៉ាកំផ្លេរអញ្ចឹងទៅយើងទៅស្លៀក ... យើងទៅរៀនអញ្ចឹងមកវិញបោក
បោកហាលអញ្ចឹងទៅយើងទៅមើលគោមើលពពែអីអញ្ចឹងទៅ
មកវិញស្អែកឡើងស្លៀកទៅទៀតទៅ ខោខ្លីមួយអាវមួយហ្នឹងហា ។

ក៖ ចាស!

ខ៖ អាចម៍ថៃអស់ហើយ ។

ក៖ អញ្ចឹងអត់បោកទេអញ្ចឹង ?

ខ៖ បោកដែរ ប៉ុន្តែវាតែមួយកំផ្លេរយើងមានអីផ្លាស់ប្តូរ ? អញ្ចឹងហា!

ក៖ ចាស! ចុះអ៊ំរ ... អំពីរឿងដែលល្អៗក្នុងជីវិតវិញ
តើរឿងដែរបងចងចាំជាងគេនៅក្នុងជីវិតដែលបងគិតថាវាជារឿងដែរល្អបំផុតរបស់បងហា
តើរឿងអីគេបង ?

ខ៖ ល្អមិនដឹងយ៉ាងមិចទេល្អ ? បើវាអត់មានអាពេលល្អហ្នឹងផង ។

ក៖ ចុះពេលដែលការប្រពន្ធអីហ់ ? ហ្នឹងហីជាពេលដែល្អ ។

ខ៖ អើ! ដល់ពេលការវា ... អាលែងសប្បាយចិត្តដែលព្រោះយើងបានប្រពន្ធហើយ (សើច)
រកស៊ីទៅចាប់ដៃគ្នាមករកស៊ីទៅបានទៅព្រឹកៗមកទល់តឡ្យូរទៅណា ។

ក៖ ចាស!

ខ៖ បា!

ក៖ ចុះពេលដែលជំនាន់ដែលបងអ៊ំរ ... នៅក្មេងៗកំពុងតែរៀនហា!
នៅក្នុងចិត្តរបស់បងប៉ងចង់ធ្វើអី ... មាន មានបំណាងចង់ធ្វើអីអត់ ?

ខៈ បំណងចេះតែចង់ហើ ប៉ុន្តែយើងទៅវាមិនរួច ។

កៈ ហ្នឹងហើ! បងអាច ... បងអាចប្រាប់ញ៉ុមបានអត់ថាបងចង់ធ្វើអីគេ ?

ខៈ ចង់ធ្វើ ... ពេទ្យធ្វើអីអញ្ចឹងទៅដែលណា! អោយតែវាមានលុយរៀនទៅធ្វើ ប៉ុនដល់វាមិនបានទៅធ្វើមិច ? ជីវិតយើងវាកំសត់ ... កំសត់ពេក ។

កៈ ចាស!

ខៈ រៀនវាមិនបានជ្រៅជ្រះទៅ ទៅ .... ដល់ពេលអញ្ចឹងមកជាចំការ ... មកធ្វើចំការវិញរែកទឹករែកភក់អីអញ្ចឹងទៅ ។

កៈ ចាស!

ខៈ ឈប់រៀនទៅយើងតស៊ូវាទៅអត់រួច ។

កៈ ចាស!

ខៈ បា! ម៉ែឪក៏គាត់ឈឺផង គាត់ដេកតែនឹងកន្ទេលដែលហ្នឹងហ៎ ឈឺម៉ាហ៊ឺតៗដែលហ្នឹង ។

កៈ ចាស!

ខៈ គាត់ទៅរកអីអោយយើងរៀន យើងទៅមើលគោក៏មិនទៅមើលដោយនេះដែល ដកសំណាបអោយគេបាន ១រយ ២រយ ១រៀល ២រៀល ហ្នឹងមក មកអោយគាត់ទៀត ។

កៈ ចាស!

ខៈ មិនដែលយកទៅចាយទេ ។

កៈ កូនល្អ ។

ខៈ បា! បាន៥កាក ១រៀលដកសំណាបអោយកុងឯងណុងហា ។

កៈ ចុះអ៊ំរ ... ចំពោះចំណងអាពាហ៍ពិពាហ៍របស់បង តើបងរៀបការមានបុត្រាបុត្រីមាណដែលបង ?

ខៈ ២! បាន២ប្រុសទាំង២ ។

កៈ គាត់ឈ្មោះអីខ្លះដែលបង ?

ខ៖ កូនបងនោះឈ្មោះ ប៉េង សុខពេជ្រ កូនពៅនោះឈ្មោះ ប៉េង ពៅ ។

ក៖ ប៉េង ពៅ ?

ខ៖ បា!

ក៖ ពៅគេហីហ្នឹងហ៎ ?

ខ៖ ពៅគេ! អស់ហើយមានអីទៀត ? វ:អស់ហើយ ។

ក៖ ហ្នឹងហី! អ័រ .... នៅក្នុងអ័រ ... ចិត្តប៉ងរបស់ហាតើបងនឹងចង់អោយពួកគាត់រៀនដល់កំរិតណា ?

ខ៖ ចាំមើលតទៅមុខទៀតហ្នឹង ដឹងអាមិចហ៎បើយើងឈឺជ្រាក់គ្រុបដែលណុង
ដឹងបានរៀនទល់ចប់ហីមិនបានហ៎ ។ ចង់អោយរៀនហាវា
រៀនអោយចប់ចុងចប់ដើមបានធ្វើការហ្នឹងគេណា ប៉ុន្តែដឹងបានមិនបានហ៎ ។

ក៖ ណាកកូនថាចង់ទៅដល់បណ្ឌិតហ៎ ។

ខ៖ ហ្នឹងហី! វាចង់ទៅយើងក៏ចង់អោយវាទៅដែរ
ប៉ុន្តែយើងតទៅមុខទៀតដឹងយើងបានលុយអោយវារៀនហីក៏អត់ ?

ក៖ ហ្នឹងហី!

ខ៖ បា! ព្រោះយើងរក
ដឹងរកបានអោយវារៀនហីក៏អត់ទេរាល់ថ្ងៃនេះជីវិតយើងមើលវាមិនឃើញណា ។

ក៖ ចាស!

ខ៖ បើមើលឃើញវាមានអី មិនដឹងជាស្អែកឬខានស្អែកហ៎ ? ព្រោះយើងឈឺ ។

ក៖ ប្រហែលនៅសល់ ៥០ឆ្នាំអីទៀតហ៎ ។

ខ៖ ហ្នឹងហី! ឡើងឈាមវាអត់ទៀងទេ រាល់ថ្ងៃថ្នាំប្រចាំការរហូតលេប ១គ្រាប់ៗរហូតហ្នឹងហា ។

ក៖ ចាស! ចុះបើក្នុងនាមបងជាឪពុក តើបងនឹងចង់ផ្តាំផ្ញើរអីខ្លះដល់កូនចៅរបស់បងជំនាន់ក្រោយ ?

ខ៖ ជាឪពុកគ្មានអីផ្តាំផ្ញើរអាលែង ... ពេលអាលែងអោយវាប្រឹងរៀនទៅ ។

កៈ ចាស!

ខៈ អើ! បានចេះដឹងទៅធ្វើការធ្វើងារហ្នឹងគេ បានលុយមកសំរាប់ចិញ្ចឹមជីវិតវាដោយ ... តទៅមុខទៀតណា ។

កៈ ចាស!

ខៈ ព្រោះឪចាស់ហើយមិនដឹងទៅបានអី ទៅជួយចិញ្ចឹមទៀតទេទល់តែវាប្រឹងខ្លួនវាដែល ។

កៈ ចុះអ៊ំរ .... កុំអោយកូនដើរតាមផ្លូវអាក្រក់សេពគបមិត្តភ័ក្កអាក្រក់អីហេ ?

ខៈ ប្រាប់ដែរមិនអោយសេពគបអាមិត្ត អាលែងអាក្រក់ណា ?

កៈ ចាស!

ខៈ អោយជួប អ! អោយដើរតែជាមួយអ្នកល្អ ។

កៈ ហ្នឹងហើ!

ខៈ ហ្នឹងហើ!

កៈ អ្នករៀនអ្នកសូត្រ ។

ខៈ អ្នករៀនអ្នកសូត្រ កុំអោយដើរទៅអាពួកខិលខូចណុង ។

កៈ ហ្នឹងហើ! ញ៉ុមសង្ឃឹមថាកូនរបស់បងនឹងអាចរៀនដល់អនុបណ្ឌិត ព្រោះអីគេចង់គេប៉ងដល់អនុបណ្ឌិតហាមិញហ្នឹងហា ។

ខៈ ចង់ហួសណុងទៀតហ៎ អោយតែមានអោយវារៀនណុងហ៎តែមិនដឹងថាវាមិច ។

កៈ ហ្វ! បានហើអនុបណ្ឌិតបានហើ! ហ្នឹងហើ! ជាចុង ...

ខៈ ខឹង ... ខឹងឪមិនបានរៀនហើបានចង់អោយកូនរៀនហ្នឹងហា ដឹងបានអោយរៀនមិនបានរកបានទៅចេះតែអោយរៀនទៅ ។

កៈ ហ្នឹងហើ! ហ្នឹងហើ! អញ្ចឹងជា ... ជាចុងក្រោយសុំអគុណដល់បងណាដែលអ៊ំរ ... ផ្តល់ឧកាសអោយញ៉ុមបានសម្ភាសន៍បងនៅថ្ងៃហ្នឹងអគុណច្រើនណាបង ។